# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទថា តុលាការកាត់ទោសខ្មែរក្រហមបាន យកអ្នកតាដំបងដែកធ្វើជាតំណាងយុត្តិធម៌

web site: hoksavann.org

ថ្ងៃទី១៣ មិថុនា ២០០៦

ក្នុងពេលថ្មីៗនេះ អ្នកចាត់ចែងកាត់ទោសខ្មែរក្រហមបានឲ្យគេឆ្លាក់រូបមួយយ៉ាងធំខ្ពស់ ដៃឆ្វេងកាន់ដំបង ដៃស្តាំចង្អុលទៅចំហៀង មានទឹកមុខមាំយ៉ាងកាចសាហាវ ។ រូបនេះគេសន្មត់ ជារូបអ្នកតាដំបងដែក ។ រូបនេះគេថា ជាតំណាងយុត្តិធម៌សំរាប់កាត់ទោសខ្មែរក្រហម ។ ទំនងជាគេយល់ថា ទាំងអ្នកដើមចោទទាំងអ្នកចុងចោទត្រូវតែនិយាយការពិត ឯតុលាការក៏ត្រូវកាត់សេចក្តីឲ្យមានយុត្តិធម៌ បើមិនដូច្នេះទេ អ្នកតាដំបងដែកនឹងកាច់ធ្វើឲ្យឈឺ ។ បើនិយាយអំពីអ្នកតាដំបងដែកវិញ តើអ្នកណាជាអ្នកតាដំបងដែក ចម្លើយគ្មាននិយាយច្បាស់លាស់ទេ ច្រើនសំអាងតាមពាក្យនិយាយតៗគ្នា គ្មានមូលដ្ឋាននិងឯកសារពិគ្រោះពិតប្រាកដទេ ។

តាមញាណទស្សនៈព្រះពុទ្ធសាសនាពោលថា ខ្មោចបិសាចព្រាយអ្នកតា ចាត់ទុកជាពួកអសុរកាយ គឺជាពួកអបាយសត្វ គឺពួកសត្វពុំមានសេចក្តីចំរើន ជាពួកមានទុក្ខ ។ ការយកខ្មោចបិសាចជាតំណាងយុត្តិធម៌ ពុំមានតម្លៃអ្វីសោះឡើយ ព្រោះខ្មោចបិសាចពុំមានសតិបញ្ញា ពុំមានគុណធម៌អ្វីឡើយ ។ លោកចាត់ទុកពួកអសុរកាយជាសត្វថោក ខ្លួនក៏ពុំអាចដោះស្រាយបានផង ។ ឯពាក្យថា បើអ្នកណានិយាយពុំពិតអ្នកតាកាច់នោះ គ្មានឯកសារជាភស្តុតាងទេ គ្រាន់តែឮនិយាយតៗគ្នាប៉ុណ្ណោះ ។

ប្រទេសកម្ពុជាជាប្រទេសគោរពព្រះពុទ្ធសាសនា ។ ព្រះពុទ្ធជាបុគលបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មានបញ្ញាញាណដ៏ខ្ពស់ ដូច្នេះព្រះអង្គជាបុគ្គលយុត្តិធម៌ ។ ពាក្យថាយុត្តិធម៌ បានសេចក្តីថា ពុំលំអៀងទៅរកអំពើបាប ឬប្រកបដោយអគតិធម៌ ។ ក្នុងការកាត់ទោសខ្មែរក្រហម គួរយកព្រះពុទ្ធរូបជាតំណាងយុត្តិធម៌សច្ចធម៌ តែបែរជាយកអ្នកតាដំបងដែក ដែលគ្រាន់តែចាំឈ្មោះ តាមការតំណាលពីមាត់មួយដល់មាត់មួយ ជាបិសាចកាចសាហាវ មកធ្វើជាតំណាងយុត្តិធម៌ទៅវិញ ។

គួរឆ្លាក់រូបព្រះពុទ្ធ ឲ្យជិតគង់សំដែងធម៌ បែបសំដែងធម្មចក្រប្រោសសត្វឲ្យស្គាល់បុណ្យបាបគុណទោស ។ ពេលធ្វើសវនាការកាត់ទោសខ្មែរក្រហម ត្រូវលើកដៃស្បថចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ក៏ដូចចំពោះមុខចៅក្រមកាត់សេចក្តី ទាំងដើមចោទទាំងចុងចោទ ។ មធ្យោបាយមួយបែបទៀត គឺយកគម្ពីរព្រះត្រៃបិដកបៃពុទ្ធសាសនា ជាតំណាងយុត្តិធម៌ ដូចប្រទេសខ្លះយកគម្ពីរនៃសាសនាគេមកជាតំណាងយុត្តិធម៌ដែរ

បើនិយាយតាមច្បាប់តុលាការក្នុងការសួរចម្លើយ គេមិនត្រូវគំរាមកំហែងបែបណាមួយឡើយ ។ ត្រូវឆ្លើយដោយសេរី ដោយគ្មានការភិតភ័យ ទាំងអ្នកដើមចោទទាំងអ្នកចុងចោទ ទាំងសាក្សីដឹងៗ ។ ឥឡូវនេះគេដាក់អ្នកតាដំបងដែក ធ្វើការគំរាមកំហែងចំពោះអ្នកដែលត្រូវឆ្លើយ ជាការខុសនឹងនីតិវិធីច្បាប់ ។ តាមធម្មតាគេតែងឲ្យមេធាវីរៀងខ្លួនដែលជាអ្នកចេះច្បាប់ មានស្មារតីរឹងមាំ ឡើងឆ្លើយជំនួសកូនក្តីដែលមិនចេះច្បាប់ មានស្មារតីទន់ខ្សោយ គឺអ្នកច្បាប់ទល់នឹងអ្នកច្បាប់ ។

ដើម្បីសម្របសម្រួលបញ្ហានេះ បើរូបអ្នកតាដំបងដែកបានធ្វើរួចហើយ ក៏ទុកប្រើការទៅចុះ ដើម្បីរក្សាប្រពៃណីជំនឿរបស់ខ្មែរ និងដើម្បីគំរាមដល់អ្នកដែលមិននិយាយការពិត ។ មួយទៀត គួរឆ្លាក់ព្រះពុទ្ធរូបមួយព្រះអង្គ ឲ្យធំដូចពោលមកហើយ ជាតំណាងយុត្តិធម៌ពិតប្រាកដ ញ៉ាំងគូក្តីឲ្យនិយាយការពិតចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ជាតំណាងយុត្តិធម៌នេះ ។ តាមច្បាប់កម្មផលរបស់ព្រះពុទ្ធសាសនា អ្នកនិយាយការពិតក្តី មិននិយាយការពិតក្តី អំពើនោះរបស់អ្នកប្រព្រឹត្តនៅតែជាផលដដែល នេះជាច្បាប់ធម្មជាតិ ។ ប៉ុន្តែញាតិសន្តានអ្នករងគ្រោះសម័យខ្មែរក្រហម គេចង់ដឹងការពិតក្នុងពេកកាត់ក្តីនេះ តើអ្នកណាសម្លាប់បងប្អូនគេ ។ យុត្តិធម៌អាចកើតមាន បើតុលាការឈរលើជំហរឯករាជ្យ កាត់សេចក្តីមិនលំអៀង មានការពិសោធន៍គ្រប់គ្រាន់ ទាំងច្បាប់ជាតិទាំងនិងច្បាប់អន្តរជាតិ មុនកាត់សេចក្តីត្រូវមានភស្តុតាងគ្រប់គ្រាន់ និងពិចារណាឲ្យបានល្អិតល្អន់ ។៚

❑ ❑

❑